ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៦១៦ អយក.ប្រក

# ប្រកាស
ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ គោករមៀត
មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ០១១ បឋ.កណ ចុះថ្ងៃទី ២០ ខែ ៤ ឆ្នាំ ២០០១ របស់នាយកសាលាបឋមសិក្សា ឃុំ កណ្ដោក ដែលមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្ដាល

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១:**- ផ្ដាច់សាលាឧបសម្ព័ន្ធ **គោករមៀត** ពីសាលាបឋមសិក្សា **កណ្ដោក** ដែលមានទីតាំងស្ថិត ឃុំ **កណ្ដោក** ស្រុក **កណ្ដាលស្ទឹង** ខេត្ត**កណ្ដាល** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២:**- សាលាបឋមសិក្សា **គោករមៀត** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:**- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:**- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត **កណ្ដាល** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កណ្ដាលស្ទឹង** នាយកសាលាបឋមសិក្សា **គោករមៀត** នាយកសាលាបឋមសិក្សា **កណ្ដោក** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
រដ្ឋលេខាធិការ

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តកណ្ដាល

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៥
- កាលប្បវត្តិ- ឯកសារ នា -ប.ម